# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២

## អូស្ត្រាលីជួយដល់មហោស្រពភាពយន្តអន្តរជាតិកម្ពុជា ដើម្បីអបអរខួបទី ៧០ឆ្នាំ នៃទំនាក់ទំនងការទូតជាមួយកម្ពុជា

ស្ថានទូតអូស្ត្រាលីជួយដល់មហោស្រពភាពយន្តអន្តរជាតិកម្ពុជា (CIFF) លើកទី ១១ នៅឆ្នាំនេះ ដែលជាផ្នែកមួយនៃខួបទី៧០ឆ្នាំ នៃការបង្កើតទំនាក់ទំនងការទូតរវាងកម្ពុជា និងអូស្ត្រាលី។ មហោស្រពភាពយន្តអន្តរជាតិកម្ពុជា ប្រព្រឹត្តទៅ ចាប់ពីថ្ងៃទី២៨ ខែមិថុនា ដល់ថ្ងៃទី3 ខែកក្កដា ហើយនឹងធ្វើកម្មវិធីបើក នៅថ្ងៃអង្គារ ទី២៨ ខែមិថុនា វេលាម៉ោង 5:30 ល្ងាច នៅសាលសន្និសីទចតុមុខ។

ឆ្នាំនេះជាឆ្នាំដ៏សំខាន់សម្រាប់ទំនាក់ទំនងអូស្ត្រាលីនិងកម្ពុជា។ ការផ្លាស់ប្តូរវប្បធម៌ និងសិល្បៈជាមធ្យោបាយមួយ ដើម្បីអបអរទំនាក់ទំនងរវាងប្រជាជននិងប្រជាជនដ៏រឹងមាំ រវាងប្រទេសអូស្ត្រាលី និងកម្ពុជា។ ការគាំទ្រពីស្ថានទូតអូស្ត្រាលីដល់កម្មវិធីមហោស្រពនេះ ត្រូវបានរៀបចំឡើងដើម្បីជួយ ផ្សារភ្ជាប់វប្បធម៌ ស្វែងរកមូលដ្ឋានរួម និងបង្កើតអារម្មណ៍រួមនៃសហគមន៍។ ខ្សែភាពយន្តនានា ដែលនឹងចាក់បញ្ចាំងនឹងឆ្លុះបញ្ចាំងពីប្រទេសអូស្ត្រាលីសហសម័យ ដែលមានភាពចម្រុះ ភាពច្នៃប្រឌិត និងសំបូរបែប។ មហោស្រពភាពយន្តនេះ ជាឱកាសសម្រាប់ប្រជាជនអូស្ត្រាលី និងកម្ពុជាទាំងអស់ ឆ្លុះបញ្ចាំងពីដំណើរនៃទំនាក់ទំនងទ្វេភាគីក្នុងរយៈពេល៧០ឆ្នាំ កន្លងមកនេះ ក៏ដូចជាអ្វីដែលយើងអាចធ្វើបាននៅក្នុង ៧០ឆ្នាំខាងមុខ និងរាប់ឆ្នាំទៅមុខទៀត។

លោក Andreas Zurburgg ភារធារីស្ថានទូតអូស្ត្រាលីបានមានប្រសាសន៍ថា «មិនខុសពីផ្នែកផ្សេងៗនៅក្នុងឧស្សាហកម្មច្នៃប្រឌិតទេ មហោស្រពភាពយន្តត្រូវបានរងការប៉ះពាល់ ដោយសារតែជំងឺកូវីដ-១៩ ក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ។ យើងរីករាយដែលមហោស្រពភាពយន្តអន្តរជាតិកម្ពុជា បានវិលត្រលប់មកវិញក្នុងឆ្នាំនេះ ដែលជាឆ្នាំទី១១ របស់ខ្លួន បន្ទាប់ពីត្រូវបានខកខានអស់រយៈពេល ២ឆ្នាំមកហើយ»។

លោក Zurbrugg បានមានប្រសាសន៍បន្ថែមថា «ដើម្បីអបអរខួបទី៧០ឆ្នាំ នៃទំនាក់ទំនងទូភាគីរវាងកម្ពុជា និងអូស្ត្រាលី យើងនឹងចាក់បញ្ចាំងភាពយន្តអូស្ត្រាលីប្រហែល២០ រឿង ដែលបានផលិតឡើងក្នុងអំឡុង ឆ្នាំ១៩៥២ ដល់ ឆ្នាំ២០២២។ ខ្សែភាពយន្តទាំងនេះរួមមាន ភាពយន្តទាក់ទងនឹងសហគមន៍ និងភាពយន្តអប់រំ ដែលបង្ហាញពីបញ្ហានានាស្តីពី បរិស្ថាននិងការគ្រប់គ្រងទឹកទន្លេមេគង្គ កសិកម្ម ក្រុមជនជាតិដើមភាគតិច និងសមភាពយេនឌ័រ»។

បន្ថែមពីលើការចាក់បញ្ចាំងជាង ១៧០ ភាពយន្តនិងឯកសារនានា យើងក៏នឹងមានផលិតករនិងសិល្បករជនជាតិអូស្ត្រាលីចំនួន ៣រូប ដែលនឹងចូលរួមនៅក្នុងកម្មវិធី មហោស្រពភាពយន្តអន្តរជាតិកម្ពុជា ឆ្នាំនេះផងដែរ ដែលមានដូចជា លោក Richard Kuipers ជាអ្នកវិភាគខ្សែភាពយន្តនិងជាអ្នករៀបចំកម្មវិធីមហោស្រពភាពយន្ត អ្នកនាង Allison Chhorn ជាសិល្បករនិងផលិតករភាពយន្តជនជាតិអូស្ត្រាលីដើមកំណើតខ្មែរ និងលោក James Gerrand ជាផលិតករភាពយន្តជើងចាស់។

អូស្ត្រាលីទន្ទឹងរង់ចាំបន្តធ្វើការជាមួយកម្ពុជាក្នុងរយៈពេល៧០ឆ្នាំខាងមុខ និងរាប់ឆ្នាំបន្តទៅមុខទៀត ដើម្បីពង្រឹងទំនាក់ទំនងទ្វេភាគីរបស់យើង និងដោះស្រាយបញ្ហាប្រឈមរួមនានា។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au